**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ១០២ ក្រ៣ "ង១"

ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣០៤៥

ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ ៣១៤១

ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ ៥៤៦៨

ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ២ និង ៣០ នាទីរសៀល នៅសាលសវនាការលេខ ៤ ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា

-លោកអនុប្រធាន [redacted] ជាចៅក្រមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣០៤៥ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ :

-ឈ្មោះ [redacted] រ៉ែត ភេទ ប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ ឆ្នាំកំណើត ១៩៨៧ កាន់សាសនាព្រះពុទ្ធ មុខរបររត់តាក់ស៊ី ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តតាកែវ ។ មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅបន្ទប់ជួលលេខ១០ ភូមិទួលគី 'សង្កាត់ភ្លើងឆេះរទេះ ខណ្ឌកំបូល រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ [redacted] ផុន (រ) ម្តាយឈ្មោះ [redacted] លឹម (រ) ប្រពន្ធឈ្មោះ [redacted] ចាន់ធីតា មានកូន ០២នាក់ ជានីតិជន កម្រិតវប្បធម៌ ថ្នាក់ទី៩ ទោសពីមុន មាន ធ្លាប់ជាប់ពន្ធនាគាររយៈពេល ៣ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ (ឃុំខ្លួន)

-ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៦១៥ "ឈ" ដ.ឃ.ដ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មានការិយាល័យតាំងនៅអគារលេខ១៥០ ជាន់ទី៤ ផ្លូវលេខ៥១៦ កាច់ជ្រុងមហាវិថីសម្តេចប៉ែននុត សង្កាត់បឹងកក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។



Scanned with CamScanner

-មានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មានការិយាល័យតាំងនៅផ្ទះលេខ៤០A ផ្លូវលេខ៣៥០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិទ្ធិ ភេទ ប្រុស អាយុ ៥៤ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៥៧ ផ្លូវលំ ភូមិថ្នល់បំបែក សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី មានការិយាល័យតាំងនៅផ្ទះលេខ៥០A ផ្លូវលេខ៣៥៨ សង្កាត់ទួលស្វាយព្រៃ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។

## អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ ៖

ឈ្មោះ [redacted] ប៉ែត ភេទ ប្រុស អាយុ ៣៣ឆ្នាំ បានលួចតាមស្រលាញ់ប្រពន្ធរបស់ឈ្មោះ [redacted] សិទ្ធិ ភេទ ប្រុស អាយុ ៥៤ឆ្នាំ ជាតិខ្មែរ ហើយក្រោយពីឈ្មោះ [redacted] សិទ្ធិ ដឹងរឿងនេះ ឈ្មោះ [redacted] សិទ្ធិ បានប្រាប់ទៅឈ្មោះ [redacted] ប៉ែត ជាច្រើនដងថា ឱ្យឈប់តាមស្រលាញ់ប្រពន្ធខ្លួន តែឈ្មោះ [redacted] ប៉ែត មិនស្ដាប់ ហើយតែងតែគំរាមសំលាប់ឈ្មោះ [redacted] សិទ្ធិ ជាច្រើនដង ។ រហូតមកដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ឈ្មោះ [redacted] សិទ្ធិ កំពុងតែផឹកទឹកត្នោតជូរជាមួយមិត្តភ័ក្រ នៅមុំរវត្តជន្លងម្លូរ ផ្លូវជាតិលេខ៣ វេលាម៉ោងប្រហែល ៧ យប់ ស្រាប់តែឈ្មោះ [redacted] ប៉ែត ជិះម៉ូតូដោយដៃខាងឆ្វេងមានកាន់កាំបិតដេញកាប់តាមពីក្រោយឈ្មោះ [redacted] សិទ្ធិ ដោយឈ្មោះ [redacted] ប៉ែត បានយារកាំបិតកាប់ទៅលើឈ្មោះ [redacted] សិទ្ធិ ចំនួន ០២ ដង តែឈ្មោះ [redacted] សិទ្ធិ គេចផុត ហើយឈ្មោះ [redacted] សិទ្ធិ បានជិះគេចទៅកន្លែងមានមនុស្សច្រើន ឈ្មោះ [redacted] ប៉ែត ក៏ជិះម៉ូតូគេចខ្លួនត្រឡប់ក្រោយបាត់តែម្ដង ។

-បានឃើញ ពាក្យបណ្ដឹង ចុះថ្ងៃទី ២៨-០៤-២០២០ របស់ឈ្មោះ [redacted] សិទ្ធិ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **៣១៩១ អ.យ.ជ** ចុះថ្ងៃទី ២៣-០៦-២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ **៤៧៧៩ អ.យ.ញ** ចុះថ្ងៃទី ០៧-០៩-២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **៦១៧២ "ឈ" ង.ង** ចុះថ្ងៃទី ១៥-០៩-២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ប៉ែត បានឆ្លើយថា : ខ្លួនសុំបដិសេធចំពោះការប្ដឹងរបស់ឈ្មោះ [redacted] សិទ្ធិ ដែលប្ដឹងខ្លួនថា កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោងប្រហែល ១៩ និង ០០ នាទី ខ្លួនបានជិះម៉ូតូយកកាំបិតដេញកាប់គាត់ ហើយខ្លួនក៏អត់ធ្លាប់បានទូរសព្ទ័ទៅគំរាមគាត់នោះដែរ ។ ខ្លួនមិនចាំថា នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួននៅទីណានោះទេ ប៉ុន្តែជាធម្មតាខ្លួននៅមើលកូនជាប្រចាំ ព្រោះប្រពន្ធខ្លួនគាត់ធ្វើការរោងចក្រ ហើយពេលយប់ខ្លួនពុំដែលចេញទៅណាទេ ។ តាំងពីតូចរហូតមកទល់សព្វថ្ងៃនេះ ខ្លួនពុំដែលដេញកាប់នរណាម្នាក់នោះទេ ហើយក៏មិនដែលឈ្លោះវាយតប់គ្នាជាមួយនរណាដែរ ។ ខ្លួនស្គាល់ឈ្មោះ [redacted] សិទ្ធិ នៅផ្ទះរបស់ឈ្មោះ [redacted] ឌី ដែលនៅក្បែរផ្ទះរបស់ឈ្មោះ [redacted] សិទ្ធិ នៅពេលដែលខ្លួនទៅខ្ចីប្រាក់ពីឈ្មោះ [redacted] ឌី ។ ឈ្មោះ [redacted] សិទ្ធិ បានសុំរាប់អានខ្លួន ហើយគាត់តែងតែទូរសព្ទ័ហៅខ្លួនផឹកជារឿយៗ ប៉ុន្តែខ្លួនពុំដែលទៅផឹកជាមួយគាត់នោះទេ ។

ចំពោះឈ្មោះ [redacted] **ទិមល** ជាប្រពន្ធរបស់ឈ្មោះ [redacted] **សិទ្ធិ** ស្គាល់ប្រពន្ធរបស់ខ្លួនមុនស្គាល់រូបខ្លួន ហើយគាត់ធ្លាប់លេងខ្លាឃ្លោកជាមួយខ្លួន នៅម្តុំផ្ទះគាត់ និងនៅជិត ង៧០ ដោយមានមនុស្សជាច្រើននាក់លេងជាមួយ ។ ឈ្មោះ [redacted] **ទិមល** ធ្លាប់ជួលរថយន្តរបស់ខ្លួនចំនួន ០២ ដង លើកទី១ ជួលនៅអំឡុងឆ្នាំ២០១៩ ទៅផ្ទះម្តាយគាត់នៅស្រុកកោះធំ ខេត្តកណ្តាល ដោយគាត់ទៅពីរនាក់កូនប្រុសគាត់ ដែលមានអាយុប្រហែល ៩ឆ្នាំ ក្នុងតម្លៃ ៤០ ដុល្លារអាមេរិក ហើយរថយន្តខ្លួន មានម៉ាកសាំយ៉ុង ១៥កៅអី ពណ៌ស និងលើកទី២ ជួលទៅលេងភ្នំបូកគោ ខេត្តកំពត ដោយគាត់ទៅជាមួយកូនគាត់ទាំងពីរនាក់ ក្នុងតម្លៃ ១២០ ដុល្លារអាមេរិក ។ រវាងខ្លួន និងឈ្មោះ [redacted] **ទិមល** គ្រាន់តែស្គាល់រាប់អានគ្នាជាធម្មតាប៉ុណ្ណោះ ពុំមានទំនាក់ទំនងស៊ីជម្រៅរឿងស្នេហាអ្វីនោះទេ ។ ខ្លួនដឹងថាឈ្មោះ [redacted] **សិទ្ធិ** ប្រច័ណ្ឌនឹងខ្លួនជាមួយប្រពន្ធគាត់ ក្រោយពេលដែលប្រពន្ធរបស់គាត់ជួលឡានរបស់ខ្លួនទាំងពីរលើក ហើយចាប់ពីពេលនោះមកគាត់តែងតែទូរសព្ទមកគំរាមខ្លួនថា ប្រយ័ត្នងាប់តាមផ្លូវ ប៉ុន្តែក្រោយមកទៀតគាត់ក៏ទូរសព្ទមកសុំរាប់អានវិញ ដោយហៅខ្លួនទៅហូបចុកជាមួយគាត់ ប៉ុន្តែខ្លួនពុំដែលទៅផឹកស៊ីជាមួយគាត់នោះទេ ។ បន្ទាប់មកទៀតមានមនុស្សស្រី ០៣នាក់ មកជួលផ្ទះក្បែរផ្ទះជួលរបស់ខ្លួន ហើយមនុស្សស្រីនោះតែងតែបបួលខ្លួនប្រើប្រាស់គ្រឿងញៀន ប៉ុន្តែខ្លួនបដិសេធមិនប្រើប្រាស់គ្រឿងញៀនទេ ក្រោយមកសមត្ថកិច្ចបានចាប់មនុស្សស្រីទាំងបីនាក់នោះពាក់ព័ន្ធនឹងគ្រឿងញៀន ហើយមនុស្សស្រីនោះបានឆ្លើយថា ខ្លួនទៅទិញថ្នាំញៀនពីគាត់យកទៅលក់បន្ត ទើបសមត្ថកិច្ចចាប់រូបខ្លួនបញ្ជូនមកតុលាការ និងឃុំខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។ មុនពេលសមត្ថកិច្ចឃាត់រូបខ្លួន ឈ្មោះ [redacted] **សិទ្ធិ** បានយករូបថតខ្លួនជាមួយប្រពន្ធរបស់ខ្លួនទៅផុសក្នុងហ្វេសបុក ដោយសរសេរថា គ្រួសារវានេះជិតវិនាស ឬ រលាយ ហើយ ដោយផុសជាច្រើនដង ។ ខ្លួនបានយករឿងនេះទៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីជម្រាបអំពីរឿងនេះ ពីព្រោះឈ្មោះ [redacted] **សិទ្ធិ** ជាមន្ត្រីកងរាជអាវុធហត្ថ ។ ពេលនោះខាងបញ្ជាការដ្ឋានបានឱ្យខ្លួនដាក់ពាក្យបណ្តឹង ប៉ុន្តែខ្លួនពុំបានដាក់ពាក្យបណ្តឹងទេ ព្រោះមិនចង់ឱ្យមានរឿងវែងឆ្ងាយ គ្រាន់តែចង់ឱ្យហៅឈ្មោះ [redacted] **សិទ្ធិ** ទៅប្រាប់ ឱ្យឈប់ធ្វើសកម្មភាពអញ្ចឹងទៀត ។ ក្រោយមកខាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានទូរស័ព្ទតាមឆាតមកខ្លួន ហៅខ្លួនឱ្យទៅតទល់ជាមួយឈ្មោះ [redacted] **សិទ្ធិ** ប៉ុន្តែដោយពេលនោះខ្លួនជាប់រវល់បុណ្យសពឪពុកក្មេកខ្លួន ទើបខ្លួនមិនបានទៅ ដោយប្រាប់ពីមូលហេតុឱ្យគាត់បានដឹង ហើយគាត់ក៏ប្រាប់ខ្លួនវិញថា បើរវល់អញ្ចឹងមិនអីទេ គាត់បានណែនាំឈ្មោះ [redacted] **សិទ្ធិ** រួចហើយ ។ ខ្លួនដឹងថាឈ្មោះ [redacted] **សិទ្ធិ** ជាមន្ត្រីកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចាប់តាំងពីដំបូងមកម្លេះ តាមរយៈឯកសណ្ឋានរបស់គាត់ និងតាមរយៈប្រពន្ធរបស់គាត់ប្រាប់ខ្លួន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សិទ្ធិ** បានឆ្លើយបញ្ជាក់ថា : ឈ្មោះ [redacted] **រ៉ែត** បានតាមស្រលាញ់ប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] **ទិមល** តែខ្លួនបានប្រាប់ឈ្មោះ [redacted] **រ៉ែត** ឱ្យឈប់ស្រលាញ់ប្រពន្ធខ្លួន ហើយឈ្មោះ [redacted] **រ៉ែត** តែងតែគំរាមសម្លាប់រូបខ្លួនរហូតមក ដោយសារខ្លួនបានរាំងរឿងនេះ ។ ឈ្មោះ [redacted] **រ៉ែត** បានតាមស្រលាញ់ប្រពន្ធខ្លួន តាំងពីខែកញ្ញា ឆ្នាំ២០១៩ ហើយបច្ចុប្បន្នប្រពន្ធខ្លួនបានចាកចេញពីផ្ទះហើយ និងមកវិញម្តងម្កាល ។ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោងប្រហែល ៥ និង ០០ នាទីរសៀល ខ្លួនបានទៅផឹកទឹកត្នោតជូរជាមួយមិត្តភ័ក្ត្រ នៅម្តុំវត្តជន្លង់ម្លូ ផ្លូវជាតិលេខ៣ លុះដល់ម៉ោងប្រហែល ៧ យប់ ខ្លួនបានត្រឡប់មកផ្ទះវិញ ស្រាប់តែខ្លួនឃើញឈ្មោះ [redacted] **រ៉ែត** ជិះម៉ូតូដេញខ្លួនពីក្រោយ ដោយដៃឆ្វេងមានកាន់កាំបិត និងដេញកាប់ខ្លួនពីក្រោយ តែកាប់មិនត្រូវ ហើយខ្លួនបានជិះម៉ូតូលឿនរហូតដល់កន្លែងមានមនុស្សច្រើន ទើបឈ្មោះ [redacted] **រ៉ែត** ឈប់ដេញខ្លួន ហើយមិត្តភ័ក្ត្រខ្លួនពីរនាក់ទៀតមានឈ្មោះ **ម៉ាប់** និងឈ្មោះ **ធូ** ក៏បានឃើញដែរ ។



Scanned with CamScanner

-ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] រតនា បានបញ្ជាក់ថា : កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ឈ្មោះ [redacted] សិទ្ធិ កំពុងតែផឹកទឹកត្នោតជូ នៅជិតវត្តជន្លង់ម្លូរ ស្រាប់តែមានជនល្មើសម្នាក់ ភេទប្រុស ពុំស្គាល់ឈ្មោះ យកកាំបិតដេញកាប់ឈ្មោះ [redacted] សិទ្ធិ តែឈ្មោះ [redacted] សិទ្ធិ បានរត់គេចខ្លួនទៅរកកន្លែងមនុស្សច្រើន ពេលនោះជនល្មើសដេញតាមពីក្រោយ ហើយឃើញមានមនុស្សច្រើន ជនល្មើសក៏រត់គេចខ្លួនបាត់ទៅ ។

-ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ចាន់ធូ បានបញ្ជាក់ថា : កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនកំពុងតែអង្គុយផឹកទឹកត្នោតជូរជាមួយឈ្មោះ [redacted] សិទ្ធិ នៅជិតវត្តជន្លង់ម្លូរ ស្រាប់តែមានជនល្មើសម្នាក់ភេទប្រុស ពុំស្គាល់ឈ្មោះ យកកាំបិតដេញកាប់ឈ្មោះ [redacted] សិទ្ធិ តែឈ្មោះ [redacted] សិទ្ធិ បានជិះម៉ូតូរត់គេចខ្លួនទៅរកកន្លែងមានមនុស្សច្រើន ពេលនោះជនល្មើសក៏ជិះម៉ូតូត្រឡប់ក្រោយគេចខ្លួនបាត់ទៅ ។

-ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ដាវី បានបញ្ជាក់ថា : ខ្លួនជាគ្រូពេទ្យទូទៅបើកគ្លីនិចឯកជនបានចេញបំរើការងាររយៈពេល ៥ឆ្នាំ មកហើយ ធ្វើនៅភូមិព្រែកកំបោះ ។ ខ្លួនចប់បាក់ឌុបឆ្នាំ២០០៩ រួចចូលរៀនពេទ្យនៅឆ្នាំ២០១០ រៀនចប់នៅឆ្នាំ២០១៣ បន្ទាប់មកខ្លួនបើកពិនិត្យ និងព្យាបាល នៅខេត្តព្រៃវែងរយៈពេល ២ឆ្នាំ ទើបនៅឆ្នាំ២០១៧ ខ្លួនមកបើកនៅភ្នំពេញវិញ ។ ខ្លួនបានព្យាបាលឈ្មោះ [redacted] ប៉ែត នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ដោយខ្លួនបានវាស់កំដៅ និងដាក់កន្សែងត្រជាក់នៅបន្ទប់របស់ឈ្មោះ [redacted] ប៉ែត នៅម៉ោង ៦ និង ៤០ នាទីល្ងាច ពេលទៅដល់ខ្លួនជួបឈ្មោះ [redacted] ប៉ែត និងកូនគាត់ពីរនាក់ មានក្មេងប្រុស អាយុប្រហែល ៦ ឆ្នាំ និងម្នាក់ទៀត អាយុ ១ឆ្នាំជាង ។ កូនគាត់ទាំងពីរនាក់ ខ្លួនធ្លាប់ព្យាបាលឲ្យពេលក្តៅខ្លួន ហើយថ្ងៃនោះខ្លួនឃើញ កូនធំរបស់គាត់នៅមិនទាន់ស្រួលខ្លួន ដោយកូនគាត់ពោះវៀនស្អិត ។ ខ្លួនមិនចាំថាឃើញម៉ូតូ ឬ អត់ទេ ពេលព្យាបាលនោះ អស់ប្រាក់ចំនួន ១៧.០០០ រៀល ។ ខ្លួនស្គាល់ឈ្មោះ [redacted] ប៉ែត បានរយៈពេល ២ឆ្នាំ មកហើយ ដោយធ្លាប់ព្យាបាលឲ្យគាត់ តែមិនធ្លាប់ទៅណាជាមួយគាត់ទេ ។ ថ្ងៃនោះឈ្មោះ [redacted] ប៉ែត ក្តៅខ្លួន និងអស់កំលាំង ខ្លួនក៏បានឲ្យកន្សែងត្រជាក់ និងឲ្យថ្នាំកំលាំង ៥អំពូល ហើយរាល់អ្នកជំពាក់ គឺខ្លួនបានកត់ទុកក្នុងសៀវភៅ ខ្លួនពុំបានចាប់អារម្មណ៍ថា ជាទឹកប៊ិចថ្មី សរសេរតូចៗតាមក្រោយបញ្ច្រៀតក្នុងទំព័រតែមួយ ខុសពីទំព័រផ្សេងៗទៀតទេ ។ ពេលខ្លួនទៅដល់បន្ទប់គាត់ មិនឃើញប្រពន្ធរបស់គាត់ទេ រីឯម៉ូតូខ្លួនមិនបានចាប់អារម្មណ៍មើលម៉ូតូ និងម្ហូបអ្វីទេ ។

-ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សុភី បានបញ្ជាក់ថា : ខ្លួនស្គាល់ប្រពន្ធរបស់ឈ្មោះ [redacted] ប៉ែត ជាអ្នកធ្វើការជាមួយគ្នានៅរោងចក្រចិនធ្វើស្បែកជើង ។ ខ្លួនស្គាល់ប្រពន្ធរបស់ឈ្មោះ [redacted] ប៉ែត បានរយៈពេល ៧ឆ្នាំ មកហើយ រីឯឈ្មោះ [redacted] ប៉ែត ខ្លួនស្គាល់បានប្រហែល ២ឆ្នាំ ដោយជួលបន្ទប់នៅក្បែរគ្នា គាត់មានកូន ២នាក់ កូនធំ អាយុ ៧ឆ្នាំ និងកូនតូច អាយុ ១ឆ្នាំ ហើយកូនបងចូលពេទ្យវះកាត់ ។ នៅថ្ងៃនោះ ខ្លួនចេញពីរោងចក្រ ពេលមកដល់បន្ទប់បានចូលអើតមើលកូនរបស់គាត់មួយភ្លែត ទើបខ្លួនឡើងទៅបន្ទប់របស់ខ្លួន រួចម៉ោង ៧ ទៅ ៨ ខ្លួនចុះមកវិញ ជួយមើលកូនឲ្យគាត់ ។ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ឈ្មោះ [redacted] ប៉ែត មិនបានចេញទៅណាទេ ហើយម៉ោង ៦ ល្ងាច ខ្លួនបានចូលមើលកូនគាត់មួយសន្ទុះ ខ្លួនក៏ឡើងទៅបន្ទប់ខ្លួនវិញ នៅថ្ងៃនោះខ្លួនមិនឃើញម៉ូតូរបស់គាត់ទេ ព្រោះប្រពន្ធគាត់ជិះទៅធ្វើការ ។ ខ្លួនជួយមើលកូនឲ្យគាត់តែមួយភ្លែតៗទេ ជារៀងរាល់ថ្ងៃ ដោយមើលបានប្រហែល ១០ ទៅ ២០ នាទី ប៉ុណ្ណោះ ខ្លួនពុំមានកូន និងគ្រួសារទេ ។ នៅថ្ងៃនោះខ្លួនឃើញឈ្មោះ [redacted] ប៉ែត និយាយជាមួយកូនគាត់ថា មិនសូវស្រួលខ្លួនទេ ហើយខ្លួនក៏ឡើងទៅបន្ទប់ងូតទឹកលុះកន្លះម៉ោងក្រោយ ទើបខ្លួនចុះមកបន្ទប់របស់ឈ្មោះ [redacted] ប៉ែត វិញ ឃើញលោកគ្រូពេទ្យកំពុងវាស់កំដៅឲ្យឈ្មោះ [redacted] ប៉ែត ។ ឈ្មោះ [redacted] ប៉ែត ជាមនុស្សស្លូតមិនដែលវៃប្រពន្ធកូន និងពុំមានទំនាស់ជាមួយនរណា



Scanned with CamScanner

ឡើយ ។ ខ្លួនពុំធ្លាប់ស្គាល់ និងឃើញឈ្មោះ [redacted] សិទ្ធិ ទេ ហើយក៏ពុំធ្លាប់ឃើញគាត់មកបន្ទប់ជួលរបស់ឈ្មោះ [redacted] ប៉ែត ទេ ។ ខ្លួនជួបលោកគ្រូពេទ្យ នៅពេលខ្លួនចុះពីបន្ទប់មកវិញ តែខ្លួនមិនបានចូលបន្ទប់គាត់ទេ ខ្លួននៅចង្ក្រានបាយខាងក្រៅបន្ទប់របស់គាត់ ។ នៅម៉ោងជិត ៧យប់ ទើបខ្លួនចូលមកយកទូរសព្ទវិញ ហើយខ្លួនមិនដឹងគាត់យកទូរសព្ទរបស់ខ្លួនខលទៅណាខ្លះទេ ។

## លោក [redacted] ជាមេធាវីការពារសិទ្ធិ ឲ្យដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើសេចក្ដីសន្និដ្ឋានថា :

ក្នុងរឿងនេះ ជនជាប់ចោទឈ្មោះ [redacted] ប៉ែត ពិតជាបានដេញកាប់កូនក្ដីខ្លួនឈ្មោះ [redacted] សិទ្ធិ ដោយមានចម្លើយស៊ីសង្វាក់ទៅនឹងសាក្សីពីរនាក់ ព្រមទាំងស៊ីសង្វាក់ទៅនឹងអង្គហេតុក្នុងសំណុំរឿងផងដែរ ហើយអំពើរបស់ជនជាប់ចោទមានធាតុផ្សំគ្រប់គ្រាន់ដែលច្បាប់បានចែង និងផ្ដន្ទាទោស ប្រាកដមែន រីឯចម្លើយរបស់ជនជាប់ចោទគ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ។ ចំពោះចម្លើយរបស់សាក្សីឆ្លើយដោះបន្ទុកនេះ ពុំអាចជឿបានឡើយ ម្យ៉ាងទៀតភស្តុតាងដែលជនជាប់ចោទដាក់ជូនតុលាការពិនិត្យ គឺជនជាប់ចោទបានលួចថតជាភស្តុតាងមិនស្របច្បាប់ ហេតុនេះសូមឲ្យតុលាការផ្ដន្ទាទោសជនល្មើសតាមច្បាប់ ។

## សេចក្ដីសន្និដ្ឋានម្ដីងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ, ដើមបណ្ដឹងរដ្ឋប្បវេណី, អំណានចម្លើយបំភ្លឺរបស់សាក្សី និងពិនិត្យភស្តុតាងក្នុងសំណុំរឿងរួចមក ឃើញថាមានភស្តុតាងដាក់បន្ទុកជូនល្មមលើសពីវិមតិសង្ស័យដែលអាចបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] ប៉ែត ភេទ ប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ ជាទីតិជន ពិតជាបានធ្វើសកម្មភាព ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។ ដូចនេះតំណាងអយ្យការស្នើសុំតម្កល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៧៧៩ អ.យ.ញ ចុះថ្ងៃទី ០៧-០៩-២០២០ ទុកជាបានការដដែល និងសូមឲ្យតុលាការសម្រេចផ្ដន្ទាទោសជនល្មើសតាមច្បាប់ ។

## លោកស្រី ពឹង ធីតា និងលោក ចាន់ ធឿន ជាមេធាវីការពារសិទ្ធិ ឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា :

ក្នុងរឿងនេះ ពាក់ព័ន្ធទំនាក់ទំនងរវាងកូនក្ដីខ្លួន និងដើមបណ្ដឹងរដ្ឋប្បវេណី ដោយទំនាស់នេះឈានដល់ការដាក់បន្ទុកកូនក្ដីខ្លួនបង្កើតជារឿង ឬ យ៉ាងណា? ព្រោះដើមបណ្ដឹងបានបែកបាក់គ្រួសារ ។ មួយវិញទៀតកូនក្ដីខ្លួនជាប្រជាពលរដ្ឋធម្មតា បើមានបញ្ហា គឺកូនក្ដីខ្លួនដាក់ពាក្យបណ្ដឹងតាមនីតិវិធីច្បាប់ ពុំមានធ្វើអ្វីខុសច្បាប់ឡើយ ។ ម្យ៉ាងទៀតដើមបណ្ដឹងរដ្ឋប្បវេណីថា កូនក្ដីខ្លួនយកកាំបិតដេញកាប់ ប៉ុន្តែពុំមានភស្តុតាងជាវត្ថុអាវុធកាំបិតនោះទេ ហើយបើមានសកម្មភាពនោះមែន មេចបានដើមបណ្ដឹងរដ្ឋប្បវេណីមិនដាក់ពាក្យបណ្ដឹងភ្លាមៗ ហើយកូនក្ដីខ្លួនពុំបានរត់គេចខ្លួនទៅណាទេ ។ នៅពេលនោះដែរ ដើមបណ្ដឹងរដ្ឋប្បវេណីមានគ្នា ៣នាក់ រីឯកូនក្ដីខ្លួនមានតែម្នាក់ឯង គឺអាចចាប់ស្ទាក់កូនក្ដីខ្លួនបាន តែដើមបណ្ដឹងមិនចាប់កូនក្ដីខ្លួនទេ ។ ចំពោះសាក្សីរបស់ដើមបណ្ដឹងថា ស្គាល់អាវរបស់ជនជាប់ចោទ តែសួរថាដើមបណ្ដឹងពាក់អាវ ពណ៌អ្វី សាក្សីមិនចាំនោះទេ ។ ប្រវត្តិកូនក្ដីខ្លួន គឺធ្លាប់មានរឿងជាបន្តបន្ទាប់ជាមួយដើមបណ្ដឹង មុនឈានមានអង្គហេតុនេះឡើង មួយវិញទៀតកូនក្ដីខ្លួនពុំមានប្រវត្តិធ្លាប់មានទំនាស់ជាមួយនរណាឡើយ ។ ដោយសារតំនុំនេះបណ្ដាលឲ្យដើម បណ្ដឹងបង្កូវរឿងហេតុ ដើម្បីទំលាក់កំហុសមកលើកូនក្ដីខ្លួន ព្រោះបើមានការប្រព្រឹត្តបទល្មើសមែន ឆន្ទះរបស់ជនល្មើសធ្វើយ៉ាង

ណាចង់ឱ្យជនរងគ្រោះមានរបួស ដូច្នេះគ្មានហេតុផលអ្វីដែលជនល្មើសត្រូវយកាកាប់ទៅលើក្បាលមានមួកសុវត្ថិភាពឡើយ ច្បាស់ជាកាប់លើខ្លួន ឬ លើចំណុចផ្សេង ដើម្បីបង្កគ្រោះថ្នាក់លើជនរងគ្រោះជាមិនខាងឡើយ ។ ប្រសិនបើមានអំពើនេះកើតឡើងមែន ដើមបណ្តឹងប្រាកដជាមិនអាចសម្ងំនៅស្ងៀមបានទេ ព្រោះធ្លាប់មានទំនាស់ជាមួយកូនក្តីខ្លួនកន្លងមកផង ច្បាស់ជាដេញតាមចាប់ ឬ ស្រែកឱ្យគេជួយអន្តរាគមន៍ភ្លាមៗជាមិនខានឡើយ ហើយច្បាស់ជាទៅប្តឹងសមត្ថកិច្ចបន្ទាប់ពីកើតហេតុរួចជាមិនខានឡើយ ។ ហេតុដូច្នេះអង្គហេតុដែលលើកឡើងដោយដើមបណ្តឹង និងសាក្សីដើមបណ្តឹងមានវិមតិសង្ស័យជាច្រើន ហើយវិមតិសង្ស័យនេះត្រូវកានជាប្រយោជន៍ដល់ជនជាប់ចោទ ដោយយោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនបានរួចផុតពីបទចោទ និងដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាព ដើម្បីបានវិលត្រឡប់ទៅជួយរកស៊ីចិញ្ចឹមកូនតូចៗនៅក្នុងបន្ទុក គ្មានអ្នកមើលថែរក្សា ដោយក្តីអនុគ្រោះ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦១៧២ "ឈ" ៥.៨ ចុះថ្ងៃទី ១៥-០៩-២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ប៉ែត ភេទ ប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ ជានីតិជន មកជំនុំជម្រះ ពីបទ ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

២. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៉ែត, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិទ្ធិ, ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] រតនា, ឈ្មោះ គុយ ចាន់ធូ និងពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] សិទ្ធិ មានភាពស៊ីសង្វាក់គ្នាអាចឱ្យតុលាការជឿជាក់ដោយគ្មានមន្ទិលថា ជនជាប់ចោទឈ្មោះ [redacted] ប៉ែត ពិតជាបានយកកាំបិតដេញកាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] សិទ្ធិ ប៉ុន្តែជនរងគ្រោះបានគេចផុត ហើយជិះទៅរកកន្លែងមនុស្សច្រើន ទើបជនជាប់ចោទជិះម៉ូតូត្រឡប់ក្រោយគេចខ្លួនបាត់ ប្រាកដមែន ។

៣. អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ប៉ែត បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈក្នុងសង្គម និងជាពិសេសប៉ះពាល់ដល់អាយុជីវិតរបស់ជនរងគ្រោះ ដែលច្បាប់ព្រហ្មទណ្ឌបានការពារដោយបញ្ញត្តិជាបទអំពើ ប៉ុនប៉ងឃាតកម្ម ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

៤. លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] ប៉ែត ពិតជាបានវេញកាប់កូនក្តីខ្លួនឈ្មោះ [redacted] សិទ្ធិ ដោយមានចម្លើយស៊ីសង្វាក់ទៅនឹងសាក្សីពីរនាក់ ព្រមទាំងស៊ីសង្វាក់ទៅនឹងអង្គហេតុក្នុងសំណុំរឿងផងដែរ ហើយអំពើរបស់ជនជាប់ចោទមានធាតុផ្សំគ្រប់គ្រាន់ដែលច្បាប់បានចែង និងផ្តន្ទាទោស ប្រាកដមែន រីឯចម្លើយរបស់ជនជាប់ចោទគ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ។ ចំពោះចម្លើយរបស់សាក្សីឆ្លើយដោះបន្ទុកនេះ ពុំអាចជឿបានឡើយ ម្យ៉ាងទៀតភស្តុតាងដែលជនជាប់ចោទដាក់ជូនតុលាការពិនិត្យ គឺជនជាប់ចោទបានលួចថតជាភស្តុតាងមិនស្របច្បាប់ ហេតុនេះសូមឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ជាសេចក្តីសន្និដ្ឋានដែលមានមូលហេតុត្រឹមត្រូវ និងភស្តុតាងគ្រប់គ្រាន់ ដើម្បីអាចឱ្យក្រុមប្រឹក្សាលើកយកមកពិចារណា និងសម្រេចតាមបាន ។

៥. តំណាងអយ្យការសន្និដ្ឋានថា មានភស្តុតាងធ្ងន់ធ្ងរលើសពីវិមតិសង្ស័យ ដែលអាចបង្ហាញថាជនជាប់ចោទឈ្មោះ [redacted] ប៉ែត ភេទ ប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ ជាតិតិជន ពិតជាបានធ្វើសកម្មភាព ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។ ដូចនេះតំណាងអយ្យការស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ ជាសេចក្តីសន្និដ្ឋានដែលមានភាពត្រឹមត្រូវគ្រប់ជ្រុងជ្រោយ គប្បីតុលាការពិចារណា និងសម្រេច ។

៦. ជនជាប់ចោទឈ្មោះ [redacted] ប៉ែត មានស្មារតីដឹងខុសត្រូវ ដឹងច្បាស់នូវអំពើដែលខ្លួនបានប្រព្រឹត្ត ហេតុនេះត្រូវទទួលខុសត្រូវនូវអំពើល្មើសរបស់ខ្លួនចំពោះមុខច្បាប់ ។

៧. មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ប៉ែត ភេទ ប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ ជាតិតិជន ពីបទ ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

៨. លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា ពាក់ព័ន្ធទំនាក់ទំនងរវាងកូនក្តីខ្លួន និងដើមបណ្តឹងរដ្ឋប្បវេណី ដោយទំនាស់នេះឈានដល់ការដាក់បន្ទុកកូនក្តីខ្លួនបង្កើតជារឿង ឬ យ៉ាងណា? ព្រោះដើមបណ្តឹងបានបែកបាក់គ្រួសារ ។ មួយវិញទៀត កូនក្តីខ្លួនជាប្រជាពលរដ្ឋធម្មតា បើមានបញ្ហា គឺកូនក្តីខ្លួនដាក់ពាក្យបណ្តឹងតាមនីតិវិធីច្បាប់ ពុំមានធ្វើអ្វីខុសច្បាប់ឡើយ ។ ម្យ៉ាងទៀតដើមបណ្តឹងរដ្ឋប្បវេណីថា កូនក្តីខ្លួនយកកាំបិតវេញកាប់ ប៉ុន្តែពុំមានភស្តុតាងជាវត្ថុអាវុធកាំបិតនោះទេ ហើយបើមានសកម្មភាពនោះមែន មេចបានដើមបណ្តឹងរដ្ឋប្បវេណីមិនដាក់ពាក្យបណ្តឹងភ្លាមៗ ហើយកូនក្តីខ្លួនពុំបានរត់គេចខ្លួនទៅណាទេ ។ នៅពេលនោះដែរ ដើមបណ្តឹងរដ្ឋប្បវេណីមានគ្នា ៣នាក់ រីឯកូនក្តីខ្លួនមានតែម្នាក់ឯង គឺអាចចាប់ស្ទាក់កូនក្តីខ្លួនបាន តែដើមបណ្តឹងមិនចាប់កូនក្តីខ្លួនទេ ។ ចំពោះសាក្សីរបស់ដើមបណ្តឹងរដ្ឋប្បវេណីថា ស្គាល់អាវរបស់ជនជាប់ចោទ តែសួរថាដើមបណ្តឹងពាក់អាវ ពណ៌អ្វី សាក្សីមិនចាំនោះទេ ។ ប្រវត្តិកូនក្តីខ្លួន គឺធ្លាប់មានរឿងជាបន្តបន្ទាប់ជាមួយដើមបណ្តឹង មុនឈានមានអង្គហេតុនេះឡើង មួយវិញទៀតកូនក្តីខ្លួនពុំមានប្រវត្តិធ្លាប់មានទំនាស់ជាមួយនរណាឡើយ ។ ដោយសារគំនុំនេះបណ្តាលឱ្យដើមបណ្តឹងបង្កនូវរឿងហេតុ ដើម្បីទំលាក់កំហុសមកលើកូនក្តីខ្លួន ព្រោះបើមានការប្រព្រឹត្តបទល្មើសមែន ឆន្ទៈរបស់ជនល្មើសធ្វើយ៉ាងណាចង់ឱ្យជនរងគ្រោះមានរបួស ដូច្នេះគ្មានហេតុផលអ្វីដែលជនល្មើសត្រូវយកកាប់ទៅលើក្បាលមានមួកសុវត្ថិភាពឡើយ ច្បាស់ជាកាប់លើខ្លួន ឬ លើចំណុចផ្សេង ដើម្បីបង្កគ្រោះថ្នាក់លើជនរងគ្រោះជាមិនខាន



Scanned with CamScanner

ឡើយ ។ ប្រសិនបើមានអំពើនេះកើតឡើងមែន ដើមបណ្តឹងប្រាកដជាមិនអាចសម្ងំនៅស្ងៀមបានទេ ព្រោះធ្លាប់មានទំនាស់ជាមួយកូនក្តីខ្លួនកន្លងមកផង ច្បាស់ជាដេញតាមចាប់ ឬ ស្រែកឱ្យគេជួយអន្តរាគមន៍ភ្លាមៗជាមិនខានឡើយ ហើយច្បាស់ជាទៅប្តឹងសមត្ថកិច្ចបន្ទាប់ពីកើតហេតុរួចជាមិនខានឡើយ ។ ហេតុដូច្នេះអង្គហេតុដែលលើកឡើងដោយដើមបណ្តឹង និងសាក្សីដើមបណ្តឹងមានវិមតិសង្ស័យជាច្រើន ហើយវិមតិសង្ស័យនេះត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដោយយោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនបានរួចផុតពីបទចោទ និងដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាព ដើម្បីបានវិលត្រឡប់ទៅជួយរកស៊ីចិញ្ចឹមកូនតូចៗនៅក្នុងបន្ទុក គ្មានអ្នកមើលថែរក្សា ជាសេចក្តីសន្និដ្ឋានដែលពុំមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់ ដើម្បីអាចឱ្យក្រុមប្រឹក្សាយកមកពិចារណា និងសម្រេចតាមបានឡើយ ។

៩. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិទ្ធិ ពុំបានប្តឹងទាមទារសំណងជម្ងឺចិត្តអ្វីទេ ហេតុនេះគប្បីតុលាការសម្រេចមិនលើកយកមកពិចារណាឡើយង ។

## ហេតុដូច្នេះសម្រេច

១/-ផ្តន្ទាទោសឈ្មោះ [redacted] ប៉ែត ភេទ ប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ ជានីតិជន ដាក់ពន្ធនាគារកំណត់រយៈពេល ១០ឆ្នាំ (ដប់ឆ្នាំ) ។

ពីបទ ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

២/-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប៉ែត, ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិទ្ធិ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ។

-បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម "

ថ្ងៃសុក្រ ១រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]